# មេរៀនទី ១៥០៖
# មិត្តភក្តិរបស់ដានីយ៉ែលគេចផុតពីគុកភ្លើងយ៉ាងសន្ធោសន្ធៅ
## ដានីយ៉ែល ៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/IxFhWslWnAA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/dmoP0lzWksY

**គោលបំណង៖** ព្រះជួយយើងឲ្យធ្វើនូវរឿងដ៏ត្រឹមត្រូវ បើទោះបីជាវាមើលទៅពិបាកក៏ដោយ។

**ខគម្ពីរចងចាំ៖ រ៉ូម១២៖២១** *"កុំឲ្យសេចក្តីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឲ្យអ្នកឈ្នះសេចក្តីអាក្រក់ ដោយសារសេចក្តីល្អវិញ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

២. ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY

៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «តំរៀបឱ្យត្រូវ»




សម្ភារៈដែលត្រូវការ៖ ស្បែកជើង៣គូខុសៗគ្នា ប្រអប់មួយ

១. ឲ្យកុមារឈរជាជួរ

២. គ្រូនឹងដាក់ស្បែកជើងម្ខាង នៃស្បែកជើងទាំង៣គូរនៅក្នុងប្រអប់មួយ ដោយមិនឲ្យកុមារដឹងនោះទេ

៣. កុមារម្នាក់ៗត្រូវដើរទៅកាន់ប្រអប់ម្នាក់ម្តង ហើយគេត្រូវព្យាយាមដាក់ស្បែងជើងឲ្យត្រូវតាមគូរបស់វា នៅក្នុងប្រអប់ ដោយមិនដឹងពីលំដាប់លំដោយដែលគ្រូបានដាក់នោះទេ

៤. នៅពេលដែលកុមារអស់ចិត្តហើយគ្រូនឹងប្រាប់កុមារថា គេដាក់ត្រូវឬខុស

៥. ប្រសិនបើកុមារដាក់ត្រូវតាមលំដាប់លំដោយនោះគេនឹងឈ្នះល្បែងនេះ តែបើគេដាក់មិនត្រូវទេនោះ គេនឹងចាញ់ល្បែងនេះ។



៦. ប្រសិនបើកុមារណាម្នាក់ដាក់ត្រូវតាមលំដាប់លំដោយ គ្រូត្រូវប្តូរទីតាំងស្បែកជើងនោះ សម្រាប់កុមារបន្ទាប់។ លេងល្បែងនេះ រហូតដល់កុមារបានលេងគ្រប់ៗគ្នា។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាពួកគេមិនបានដឹងពីលំដាប់លំដោយ នៅក្នុងប្រអប់ក៏ដោយ គឺមានកុមារខ្លះអាចដាក់ត្រូវតាមលំដាប់លំដោយនោះ។ ក៏ដូចគ្នានេះដែរ ប្រសិនបើយើងនៅជាប់ជាមួយព្រះ ទ្រង់នឹងជួយដល់យើងឲ្យឆ្លងកាត់ឧបសគ្គទាំងអស់នោះបាន។

### ៤. ការណែនាំមេរៀន

តើអ្នកតែងតែធ្វើនូវរឿងដ៏ត្រឹមត្រូវដែរឬទេ? មានពេលខ្លះអ្នកមិនមានអារម្មណ៍ថាអ្នកចង់ជ្រើសរើសនូវអ្វីដែលត្រឹមត្រូវ? ពេលខ្លះយើងជ្រើសរើសធ្វើនូវរឿងដែលយើងមិនចង់ធ្វើវា។ នៅពេលដែលជ្រើសរើសធ្វើនូវរឿងដ៏ត្រឹមត្រូវ មិនខ្វល់ថាអ្នកមានអារម្មណ៍បែបណានោះទេ តែអ្នកបានធ្វើឲ្យព្រះសព្វព្រះហឫទ័យ។

នៅចំពោះមុខ ព្រះបានផ្តល់សេចក្តីសង្ឃឹម និងជួយយើងឲ្យធ្វើនូវរឿងត្រឹមត្រូវបើទោះបីជាវាពិបាកក៏ដោយ។ ថ្ងៃនេះ យើងនឹងរៀនពីមិត្តសំលាញ់បីនាក់បានជ្រើសរើសធ្វើនូវរឿងត្រឹមត្រូវ បើទោះបីជារឿងនោះគម្រាមកំហែងដល់ជីវិតពួកគេក៏ដោយ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះយើងនឹងរៀនពីរបៀបដែលព្រះជួយយើងឲ្យធ្វើនូវរឿងដ៏ត្រឹមត្រូវបើទោះបីជាវាពិបាកធ្វើក៏ដោយ។ រឿងនៅក្នុងព្រះគម្ពីរដែលបង្ហាញនេះគឺទាក់ទងទៅនឹង សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ។ តើអ្នកធ្លាប់បាន លឺឈ្មោះពួកគេដែលឬទេ? តោះនិយាយតាមខ្ញុំ - សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ។

ពួកគាត់ទាំងបីនាក់គឺជាមិត្តភក្តិរបស់ដានីយ៉ែល។ ពួកគេត្រូវបានចាប់ជាឈ្លើយទៅស្រុកបាប៊ីឡូន ហើយពួកគេត្រូវទៅបម្រើស្តេចនៃស្រុកបាប៊ីឡូន។ ស្តេចនេប៊ូក្នេសា ជាស្តេចរបស់បាប៊ីឡូនបានបង្កើតរូបព្រះមួយដ៏ខ្ពស់មួយធ្វើពីមាសហើយឲ្យមនុស្សគ្រប់គ្នាថ្វាយបង្គំរូបព្រះនោះ។ មិត្តភក្តិទាំងបីនាក់របស់ដានីយ៉ែល សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ក៏ត្រូវបានគេប្រាប់ឲ្យទៅថ្វាយបង្គំរូបព្រះមាសនោះដែរ ប៉ុន្តែពួកគេទាំងបីនាក់បានបដិសេធ ហើយបន្តថ្វាយបង្គំព្រះពិតតែមួយប៉ុណ្ណោះ។ នេះគឺមិនមែនជាការសម្រេចចិត្តដ៏ងាយស្រួលនោះទេ ពីព្រោះថាពួកគេនឹងត្រូវកាត់ទោសប្រហារជីវិតប្រសិនបើ ពួកគេមិនធ្វើតាមរាជបញ្ជារបស់ស្តេច។ ស្តេចគឺខឹងជាខ្លាំងហើយបានបញ្ជាឲ្យទាហានចងពួកគេឲ្យជាប់រួចបោះចូលទៅក្នុងគុកភ្លើង។ គុកភ្លើងនោះគឺពិតជាក្តៅខ្លាំងណាស់ សូម្បីតែអ្នកដែលបោះ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ក៏ត្រូវ បានស្លាប់ដោយសារអណ្តាតភ្លើងដែរ។

ប៉ុន្តែនៅពេលដែលស្តេចមើលទៅក្នុងគុកភ្លើងគាត់បានឃើញបុរស៤នាក់ កំពុងដើរនៅក្នុងភ្លើងនោះ ឥតមានជាប់ចំណង ហើយក៏មិនមានគ្រោះថ្នាក់អ្វីទាំងអស់! ព្រះគម្ពីរមិនបាននិយាយថា បុគ្គលទី៤នោះគឺជានរណានោះទេ ប៉ុន្តែប្រហែលជាទេវតា ឬអាចជាព្រះយេស៊ូវក៏ថាបាន។ នៅពេលដែល សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ដើរចេញពីភ្លើងគឺពួកគេមិនមានរលាកអ្វីបន្តិចសោះ សូម្បីតែខោអាវ - ក៏មិនមានក្លិនផ្សែង ហើយក៏មិនមានសញ្ញាបញ្ជាក់ថា ពួកគេត្រូវភ្លើងឆេះអ្វីទាំងអស់! ពេលនោះស្តេចក៏បានដឹងថា ព្រះរបស់ពួកគេគឺជាព្រះពិតតែមួយ។

ការជ្រើសរើសក្នុងការថ្វាយបង្គំព្រះពិតតែមួយ មិនមែនជារឿងងាយស្រួលនោះទេសម្រាប់មិត្តភក្តិទាំង បីនាក់នោះ។ ប៉ុន្តែពួកគេសម្រេចចិត្តក្នុងការស្តាប់បង្គាប់ព្រះ ជំនួសឲ្យការស្តាប់តាមស្តេច ហើយពួកគេជឿថាព្រះនឹងជួយពួកគេ។ ហើយក៏មានបុគ្គលជាច្រើនទៀតនៅក្នុងព្រះគម្ពីរក៏បានសម្រេចចិត្តធ្វើនូវរឿងត្រឹមត្រូវ បើទោះបីជាវាផ្តល់ផលពិបាកដល់ពួកគេក៏ដោយ។

ម៉ូសេបានសម្រេចចិត្តនាំជនជាតិអ៊ីស្រាអែលចេញពីអេហ្ស៊ីប បើទោះបីជាគាត់ដឹងថាគាត់ ត្រូវបាត់បង់គ្រួសារ និងទ្រព្យសម្បត្តិទាំងអស់ដែលគាត់មាននៅអេហ្ស៊ីបក៏ដោយ។ អេសធើបានស្នើសុំឲ្យស្តេចសង្គ្រោះប្រជាជនរបស់នាង បើទោះបីជានាងដឹងថាស្តេចនឹងខឹងហើយអាចសម្លាប់នាងក៏ដោយ។ ពួកសិស្សរបស់ព្រះយេស៊ូវ បានប្រាប់មនុស្សផ្សេងទៀតអំពីព្រះយេស៊ូវ បើទោះបីជាពួកគេដឹងថា មនុស្សទាំងនោះអាចនឹងសើចចំអកឲ្យពួកគាត់ បដិសេធ ឬប្រឈមមុខនឹងសេចក្តីស្លាប់ក៏ដោយ។ ពួកគេបានជ្រើសរើស ធ្វើនូវរឿង ត្រឹមត្រូវ ដោយមិនខ្វល់ពីអ្វីទាំងអស់។ នេះគឺជាជំនឿ!

ព្រះគឺពិតជាល្អខ្លាំងណាស់សម្រាប់ពួកយើងពីព្រោះទ្រង់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធឲ្យមកជួយដល់ពួកយើង! ទ្រង់មិនចង់ឲ្យយើងធ្វើកិច្ចការនោះតែម្នាក់ឯងនោះទេ។ ដូច្នេះនៅពេលដែលយើងមានអារម្មណ៍ថាមិនចូលចិត្តអ្វីមួយ នៅពេលដែលអ្នកមានការភ័យខ្លាច ឬប្រឈមមុខនឹងសេចក្តីស្លាប់ក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធ នឹងជួយដល់អ្នកឲ្យឈរមាំសម្រាប់ព្រះអង្គ ហើយធ្វើនូវអ្វីដែលត្រឹមត្រូវ ដោយមិនខ្វល់ពីអ្វីទាំងអស់។ ទ្រង់នឹងជួយអ្នកឲ្យរឹងមាំ!

## ៦. សំនួរពិភាក្សា

១. តើមិត្តភក្តិទាំងបីនាក់នោះមានឈ្មោះអ្វីខ្លះ? *(សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ)*
២. ហេតុអ្វីបានជាស្តេច នេប៊ូក្នេសា ជាស្តេចរបស់ បាប៊ីឡូនខឹងនឹងពួកគេ?

*( ពួកគេបដិសេធ មិនថ្វាយបង្គំរូបព្រះដែលស្ដេចបានបង្កើត ហើយនៅបន្តថ្វាយបង្គំព្រះពិតតែមួយ )*
៣. តើអ្វីគឺជាការដាក់ទោសសម្រាប់មិត្តភក្តិទាំងបី? *( បោះចូលទៅក្នុងគុកភ្លើង )*

៤. តើស្ដេចនេប៊ូក្នេសាដឹងថាព្រះបានជួយសង្គ្រោះដល់មិត្តភក្តិទាំងបីដោយរបៀបណា?
*( ទ្រង់បានឃើញបុរស៤នាក់ដើរចេញពីគុកភ្លើង ប៉ុន្តែ គឺមានតែបុរស៣នាក់ប៉ុណ្ណោះដែលបានបោះចូលទៅ ហើយពួកគេគឺមិនមានស្នាមភ្លើងឆេះអ្វីទាំងអស់នៅពេលដែលពួកគេចេញមកវិញ )*
៥. តើនរណាដែលនឹងជួយយើងឲ្យធ្វើនូវរឿងត្រឹមត្រូវនៅក្នុងជីវិត? *( ព្រះនឹងតែងតែជួយដល់យើង )*

## ៧. ល្បែងកំសាន្ត «រទេះភ្លើង»

១. ឲ្យកុមារឈរជាជួរហើយតោងចង្កេះគ្នា
២. គ្រូត្រូវឈរនៅខាងមុខគេធ្វើជាក្បាលរទេះភ្លើង
៣. កុមារត្រូវតោងគ្នាឲ្យជាប់ ហើយធ្វើកាយវិការតាមគ្រូ។
គ្រូអាចរំលងកៅអី លូនក្រោមតុ ហើយផ្លាស់ ទីទៅឆ្វេងឬទៅស្តាំ ។ល។




៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា
បើទោះបីជាពួកគេធ្វើតាមគ្រូក៏ដោយ គឺពួកគេនៅតែមានការពិបាក។ នៅពេលដែលយើងដើរតាមព្រះ យើងក៏នៅតែមានពេលពិបាកដូចគ្នា។ ប៉ុន្តែ យើងត្រូវតែមានជំនឿ និងទុកចិត្តលើព្រះ ដូច្នេះ ទ្រង់នឹងតែងតែជួយដល់យើងឲ្យ ធ្វើនូវរឿងត្រឹមត្រូវបើទោះបីជាវាពិបាកក៏ដោយ។

## ៨. ខគម្ពីរចងចាំ

**រ៉ូម១២៖២១** *"កុំឲ្យសេចក្ដីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឲ្យអ្នកឈ្នះសេចក្ដីអាក្រក់ ដោយសារសេចក្ដីល្អវិញ "*

**៩. ហត្ថកម្ម** ផាត់ពណ៌រូបភាព - **"មិត្តភក្តិរបស់ដានីយ៉ែលគេចផុតពីគុកភ្លើងយ៉ាងសន្ធោរសន្ធៅ"**
សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម
១. សូមពន្យល់កុមារពីរឿងនៅក្នុងព្រះគម្ពីរម្ដងទៀតដោយប្រើប្រាស់ក្រដាសរូបភាព២សន្លឹក ហើយឲ្យកុមារសរសេរនូវខគម្ពីរចងចាំ។

**១០. ចំរៀង** *( រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន )**
ព្រះយេស៊ូវអាចទាក់ទងទៅនឹងការសាកល្បងនៅចំពោះមុខយើង ថាតើយើងឈរនៅខាងព្រះដែរទេ ពីព្រោះទ្រង់ចង់ឲ្យយើងមានបទពិសោធន៍ - ថែមហើយថែមទៀត។ ការឈរមាំសម្រាប់ព្រះគឺតែងតែទទួលបានរង្វាន់ តែវាមិនតែងតែងាយស្រួលនោះទេ។ តើអ្នកធ្លាប់ប្រឈមមុខជាមួយនឹងកាលៈ ទេសៈណាមួយ ដែលជាការសាកល្បងណាមួយហើយអ្នកនៅតែឈរមាំខាងព្រះដែរឬទេ? តើអ្នកត្រៀមខ្លួនសម្រាប់ ការសាកល្បងនោះហើយឬនៅ? សូមទុកចិត្តលើទ្រង់។ នៅពេលដែលយើងក្រោកឈរសម្រាប់ទ្រង់ ព្រះអង្គនឹងជួយដល់យើង ការពារយើង ហើយនឹងផ្ដល់រង្វាន់សម្រាប់យើងផងដែរ។ ទ្រង់សព្វព្រះទ័យ នៅពេលដែលយើងថ្វាយបង្គំទ្រង់ ហើយទ្រង់គឺមិនដែលមើលរំលងទេ។

# មិត្តភក្តិរបស់ដានីយ៉ែលគេចផុតពីគុកភ្លើងយ៉ាងសន្ធោសន្ធៅ





សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________